00226071

D99/3/19

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៦ តុលា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06, OCT, 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

សាធារណៈ

**សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មវត្ថុក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06, OCT, 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C. * C.E.T.C.

00226072



១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញថា នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងរឿងក្តីលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (“បណ្តឹងឧទ្ធរណ៍”)។

២. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលបានដាក់នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាស្នើឱ្យអង្គបុរេជំនុំជម្រះធ្វើការកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងចោទប្រកាន់ជនត្រូវចោទថា បានប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

៣. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ សហមេធាវីការពារក្តីរបស់លោក អៀង សារី បានដាក់ “សំណើជាបន្ទាន់សុំដាក់អំណះអំណាងស្តីពី ការអនុវត្តន៍នូវការទទួលខុសត្រូវ ជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់កាំង ហ្កេកអ៊ាវ ហៅ “ឌុច”” (“សំណើ”)។ នៅក្នុងសំណើនេះ សហមេធាវីការពារក្តី ស្នើសុំអង្គបុរេជំនុំជម្រះ “ផ្តល់សិទ្ធិឱ្យមេធាវីការពារដាក់ជូនសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ទៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាដំណោះស្រាយលើករណីរបស់ ឌុច នៅក្នុងរយៈពេល ១៥ថ្ងៃគិតពីថ្ងៃចេញសេចក្តីសម្រេចមក។”[១]

៤. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ថា ភាគីត្រូវដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសំណើនេះ ក្នុងរយៈពេលបី(៣)ថ្ងៃ។

៥. សហមេធាវីការពារក្តីរបស់ ឌុច និងសហព្រះរាជអាជ្ញា បានដាក់សេចក្តីសន្និដ្ឋានតបនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨។ ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

៦. នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ សហមេធាវីការពារក្តីរបស់លោក អៀង សារី បានដាក់សំណើសុំកែប្រែសំណើដើមរបស់ខ្លួន ដោយព្យាយាមស្នើសុំពន្យារកាលបរិច្ឆេទកំណត់ដាក់សេចក្តីសន្និដ្ឋាន ទៅថ្ងៃទី២៧

[១] សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍នូវការទទួលខុសត្រូវជាទម្រង់ សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ D99/3/6 ទំព័រទី ៣។

ខែតុលា ឆ្នាំ២០០៨ ដែលកាលបរិច្ឆេទនេះ ត្រូវបានអង្គបុរេជំនុំជម្រះកំណត់ឱ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដាក់សារណា ("សំណើកែប្រែ")។

៧. នៅក្នុងសំណើរបស់ខ្លួន សហមេធាវីសន្និដ្ឋានថា "ការអនុវត្តន៍ការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ប៉ះពាល់ដល់លោក អៀង សារី ដោយសារតែគាត់ត្រូវបានគេចោទប្រកាន់ថាជាផ្នែកមួយនៅក្នុង "ផែនការណ៍ឧក្រិដ្ឋរួម" តែមួយ ដូចនឹង ឌុច ដែរ។ នៅក្នុងកាលៈទេសៈនេះ លោក អៀង សារី មានផលប្រយោជន៍ជាក់លាក់នៅក្នុងការចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍នេះ។ ដូច្នេះហើយ គាត់ត្រូវតែអនុញ្ញាតឱ្យដាក់សារណានៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។"[២]

៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា លោក អៀង សារី មិនមែនជាភាគីនៅក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស ទេ។ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាបំបែករឿងក្តី នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧[៣] ឌុច ត្រូវបានចោទប្រកាន់ដាច់តែឯង នៅក្នុងរឿងក្តីនេះ។

៩. វិធានផ្ទៃក្នុងមិនមានចែងអំពីសិទ្ធិរបស់តតីយជន ក្នុងការចូលអន្តរាគមន៍នៅក្នុងសំណុំរឿង និងដាក់សារណាលើបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏មិនបានចែងអំពីបញ្ហានេះដែរ។

១០. អនុលោមតាមវិធានផ្ទៃក្នុង មានតែភាគីនៃរឿងក្តីប៉ុណ្ណោះ ដែលរួមមាន "សហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី"[៤] អាចធ្វើការទាមទារសិទ្ធិធ្វើសេចក្តីសន្និដ្ឋាន មុនពេលអង្គបុរេជំនុំជម្រះចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍។ សិទ្ធិនេះអាចទទួលបានតាមរយៈវិធាន ៧៧(៣) និងវិធាន ៧៧(១០)នៃវិធានផ្ទៃក្នុង ដែលចែងថា អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ "ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ" ឬប្រសិនបើមានសវនាការ "សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគី អាចធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយសង្ខេប"។

---

[២] សំណើ វាក្យខណ្ឌទី១។ សូមអានផងដែរនូវ វាក្យខណ្ឌទី៨ និងវាក្យខណ្ឌទី១០ នៃសំណើនេះ។

[៣] ដីកាបំបែករឿងក្តី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ D18។

[៤] និយមន័យនៃពាក្យ "ភាគី" នៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង។

១១. អង្គបុរេជំនុំជម្រះរំលឹកថា នៅក្នុងករណីបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលប្តឹងប្រឆាំងចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបើកលទ្ធភាពឱ្យដាក់សេចក្តីសន្និដ្ឋានតបទៅនឹងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង ធារី ស្នើសុំការពិចារណាជាថ្មីចំពោះសេចក្តីសម្រេចលើកមុនលើដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងនៅក្នុងសំណុំរឿងដោយឡែក។[៥] សេចក្តីអញ្ជើញនេះត្រូវបានធ្វើឡើង នៅក្នុងកាលៈទេសៈដែលថា ការចេញសេចក្តីសម្រេចលើពាក្យសុំ អាចនាំដល់ការចេញសេចក្តីបង្គាប់ជាទូទៅលើ សិទ្ធិនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ។[៦] នៅក្នុងរឿងក្តីនេះ សេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះនឹងអនុវត្តផ្ទាល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងដោយឡែក។

១២. បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាគឺ ពាក់ព័ន្ធនឹងបទចោទដែល ឌុច ត្រូវបានបញ្ជូនទៅជំនុំជម្រះ។ ដូច្នេះ សេចក្តីសម្រេចដែលនឹងចេញដោយអង្គបុរេជំនុំជម្រះ នឹងមិនអនុវត្តផ្ទាល់ ចំពោះលោក អៀង សារី ឡើយ ដែលគាត់នៅមានលទ្ធភាពតវ៉ាការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿង លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដែលគាត់ ជាភាគីនៃរឿងក្តី។

១៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ទៀតថា សហព្រះរាជអាជ្ញាមិនបានកំណត់ថា លោក អៀង សារី គឺជាសមាជិកមួយរូបនៅក្នុងក្រុមបុគ្គល ដែលបានចូលរួមនៅក្នុងការចោទប្រកាន់អំពីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងដីកាសន្និដ្ឋានស្ថាពរ និងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ នៃរឿងសំណុំរឿងនេះឡើយ។ ការអះអាងរបស់សហមេធាវីការពារក្តីថា " [ប្រសិនបើ] ការទទួលខុសត្រូវក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ត្រូវយកមកអនុវត្តចំពោះ ឌុច ដូច្នេះការអនុវត្តន៍ទ្រឹស្តីនេះចំពោះលោក អៀង សារី ដែលស្ទើរតែជៀសមិនរួច"[៧] គ្មានមូលដ្ឋានឡើយ។

១៤. អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាជាមូលដ្ឋានសម្រាប់តុលាការ ចំពោះកិច្ចដំណើរការនីតិវិធីមួយចំនួនដែលកំពុងរង់ចាំដំណោះស្រាយ ដែលថា សេចក្តីសម្រេចលើអង្គច្បាប់នៅក្នុងរឿងក្តីមួយ នឹងជាសេចក្តីណែនាំដល់តុលាការចំពោះរឿងក្តីស្រដៀងគ្នាលើកក្រោយ នៅពេលដែលមិនមានអំណះអំណាង

---

[៥] សេចក្តីណែនាំបន្ថែមទាក់ទងនឹងពាក្យសុំឱ្យពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ C22/I/59។

[៦] រឿងក្តីលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សេចក្តីបង្គាប់ស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ C22/I/69។

[៧] សំណើ វាក្យខណ្ឌទី ៨។

ឬកាលៈទេសៈថ្មីត្រូវបានលើកឡើង។ ស្ថានភាពនេះមិនបង្ហាញជាលទ្ធផលថា ជនត្រូវចោទមានសិទ្ធិអន្តរាគមន៍នៅក្នុងសំណុំរឿង ដែលខ្លួនមិនមែនជាភាគី ដើម្បីផ្តល់ការយល់ឃើញរបស់ខ្លួនលើបញ្ហាណាមួយឡើយ។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

បដិសេធចោលសំណើ និងសំណើកែប្រែ។ ៧

ភ្នំពេញ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C.

**ប្រាក់ គឹមសាន**